**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
លេខ : ៤២៥ ប្រក ប.ស្ក

# ប្រកាស
# ស្តីពី
# ការបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួង ស្តីពីការប្រើប្រាស់ និងការបែងចែកផលប្រយោជន៍ធនធានពន្ធុ

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ/បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ៥៩ អនក្រ/បក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៤ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៥ ស្តីពីការអនុម័តយល់ព្រមលើពិធីសារណាហ្គូយ៉ាស្តីពី "សិទ្ធិទទួលផលពីធនធានសេនេទិក និងការបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានសេនេទិក ដោយស្មើភាព និងសមធម៌" នៃអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ
- យោងតាមសំណើរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួងស្តីពី "ការប្រើប្រាស់ និងការបែងចែកផលប្រយោជន៍ធនធានពន្ធុ" ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. តំណាងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព | ប្រធាន |
| ២. តំណាងអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន | អនុប្រធានទី១ |
| ៣. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធានទី២ |
| ៤. តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៥. តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ៦. តំណាងក្រសួងយុត្តិធម៌ | សមាជិក |
| ៧. តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៨. តំណាងក្រសួងទេសចរណ៍ | សមាជិក |
| ៩. តំណាងអគ្គនាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១០.តំណាងនាយកដ្ឋានកម្មសិទ្ធបញ្ញានៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១១.តំណាងអគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១២.តំណាងរដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៣.តំណាងរដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៤.តំណាងមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របុរាណ នៃក្រសួងសុខាភិបាល | សមាជិក |
| ១៥.តំណាងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា | សមាជិក |
| ១៦.តំណាងសកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ១៧.តំណាងវិស័យឯកជន/សហគមន៍ជនជាតិដើមភាគតិច | សមាជិក |
| ១៨.នាយកដ្ឋានជីវៈចម្រុះ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព | លេខាធិការដ្ឋាន។ |

**ប្រការ ២.-**

ក្រុមការងារបច្ចេកទេសអន្តរក្រសួងនេះមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំបង្កើតគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត យុទ្ធសាស្ត្រជាតិ គោលការណ៍ណែនាំ និងក្របខណ្ឌការងារជាតិ ស្តីពីការប្រើប្រាស់ និងការបែងចែកផលប្រយោជន៍ធនធានពន្ធុ
- រៀបចំចងក្រង និងធ្វើបច្ចុប្បន្នភាពព័ត៌មាន និងទិន្នន័យ ពាក់ព័ន្ធនឹងការប្រើប្រាស់ និងការបែងចែកផលប្រយោជន៍ធនធានពន្ធុ និងធនធានជីវៈចម្រុះ

- សហការសម្របសម្រួល ពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃលើការអនុវត្តគម្រោងនានាពាក់ព័ន្ធនឹងធនធានពន្ធុ និងលក្ខណៈវិនិច្ឆ័យសម្រាប់ប្រភេទ និងធនធានពន្ធុដែលងាយរងគ្រោះ និងទទួលរងការគំរាមកំហែង ដើម្បីលើកជាអាទិភាពអភិរក្ស
- សម្របសម្រួល និងផ្តល់យោបល់លើការបង្កើតផែនការ និងកម្មវិធីពង្រឹងសមត្ថភាពស្តីពីការប្រើប្រាស់ និងការបែងចែកផលប្រយោជន៍ធនធានពន្ធុ និងការអនុវត្តពិធីសារណាហ្គូយ៉ាស្តីពី "សិទ្ធិទទួលផលពីធនធានសេនេទិក និងការបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានសេនេទិក (ធនធានពន្ធុ) ដោយស្មើភាព និងសមធម៌"
- សហការរៀបចំ និងចូលរួមកិច្ចប្រជុំ សិក្ខាសាលាពិគ្រោះយោបល់ និងវគ្គបណ្តុះបណ្តាលទាក់ទងនឹងពិធីសារណាហ្គូយ៉ា និងកិច្ចប្រជុំនានារបស់ក្រុមការងារបច្ចេកទេសអន្តរក្រសួងតាមការអញ្ជើញរបស់ប្រធានក្រុមការងារ
- សហការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ អង្គការដៃគូជាតិ-អន្តរជាតិ ដៃគូអភិវឌ្ឍន៍ គ្រឹះស្ថានអប់រំ វិស័យឯកជន ជនជាតិដើមភាគតិច ដើម្បីអនុវត្តគោលនយោបាយជាតិ និងយុទ្ធសាស្ត្រពាក់ព័ន្ធនឹងការប្រើប្រាស់ និងការបែងចែកផលប្រយោជន៍ធនធានពន្ធុ និងការអនុវត្តពិធីសារណាហ្គូយ៉ា
- សហការសម្របសម្រួល និងចូលរួមរៀបចំរបាយការណ៍ជាតិដាក់ជូនថ្នាក់ដឹកនាំដើម្បីពិនិត្យ និងសម្រេច មុនផ្ញើជូនទៅលេខាធិការដ្ឋានអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ
- អនុវត្តការងារផ្សេងៗទៀតតាមការចាត់តាំងរបស់ប្រធានក្រុមការងារតាមការចាំបាច់។

**ប្រការ ៣.-**

ប្រធានក្រុមការងារបច្ចេកទេសអន្តរក្រសួង មានភារកិច្ចទទួលខុសត្រូវរួម ក្នុងការដឹកនាំក្រុមការងារ។ អនុប្រធានមានភារកិច្ចជួយប្រធាន និងដឹកនាំក្រុមការងារនៅពេលអវត្តមានរបស់ប្រធាន។ សមាជិកក្រុមការងារត្រូវអនុវត្តភារកិច្ចដូចមានចែងក្នុងប្រការ២ ឱ្យមានប្រសិទ្ធភាព។

**ប្រការ ៤.-**

ក្រុមការងារបច្ចេកទេសអន្តរក្រសួងនេះ មាននាយកដ្ឋានជីវៈចម្រុះ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពជាលេខាធិការដ្ឋាន និងមានសិទ្ធិប្រើប្រាស់ត្រារបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។

**ប្រការ ៥.-**

លេខាធិការដ្ឋាន នៃក្រុមការងារបច្ចេកទេសអន្តរក្រសួងនេះ មានតួនាទី និងភារកិច្ចជាជំនួយការផ្ទាល់របស់ប្រធាន និងអនុប្រធានក្រុមការងារ ក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាល និងការងារដូចមានចែងក្នុងប្រការ២ ដើម្បីអនុវត្តការងារឱ្យមានប្រសិទ្ធភាព។

ទ.ក.ប.ស ។

**ប្រការ ៦.-**

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានគាំពារបរិស្ថាន អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ខុទ្ទកាល័យរដ្ឋមន្ត្រី ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី និងជាប្រធាន**

**ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព**

**សាយ សំអាល់**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ដូចប្រការ៦ (ដើម្បីអនុវត្ត)
- ឯកសារ កាលប្បវត្តិ